**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ១៨៧៤៨ ព.ណ.ន.ជ.ពាកព

ថ្ងៃអង្គារ ១កើត ខែជេស្ឋ ឆ្នាំមមីអដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី ២ ខែមិថុនា ឆ្នាំ ២០២៦

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ លោក-លោកស្រី ជាពាណិជ្ជករ និងសាធារណជនទូទៅឱ្យបានជ្រាបថា ទីប្រឹក្សាពាណិជ្ជកម្មក្រៅប្រទេស របស់សាធារណរដ្ឋបារាំង នឹងរៀបចំ «វេទិកាសេដ្ឋកិច្ចសម្រាប់តំបន់អាស៊ីអាគ្នេយ៍» នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៦ នៅទីក្រុងលីយ៉ុង សាធារណរដ្ឋបារាំង។ វេទិកានេះ នឹងប្រមូលផ្តុំអ្នកជំនាញ ដៃគូអភិវឌ្ឍន៍ និងតួអង្គ សេដ្ឋកិច្ចសំខាន់ៗជាច្រើន ចូលរួមពិភាក្សាផ្លាស់ប្តូរយោបល់អំពីការលើកកម្ពស់កិច្ចសហប្រតិបត្តិការការអភិវឌ្ឍភាពជាដៃគូ និងផ្សព្វផ្សាយអំពីសក្តានុពលសេដ្ឋកិច្ច របស់ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ចំនួន៦ រួមមាន កម្ពុជា ឥណ្ឌូណេស៊ី ម៉ាឡេស៊ី សិង្ហបុរី ថៃ និងវៀតណាម។ ភាគីបារាំងនឹងផ្តល់ឱ្យបណ្តាក្រុមហ៊ុន សហគ្រាស និងភាគីពាក់ព័ន្ធរបស់កម្ពុជាចូលរួមក្នុងកម្មវិធីខាងលើដោយឥតគិតថ្លៃ ប៉ុន្តែរាល់ការចំណាយផ្សេងៗជាបន្ទុករបស់អ្នកចូលរួម។

ក្រសួងពាណិជ្ជកម្ម ក្នុងនាមអ្នកសម្របសម្រួលព្រឹត្តិការណ៍ខាងលើ សូមអញ្ជើញលោក-លោកស្រី ដែលជាពាណិជ្ជករ និងសាធារណជន ដែលមានចំណាប់អារម្មណ៍ចង់ចូលរួមវេទិកាខាងលើ សូមទំនាក់ទំនងជាមួយទីប្រឹក្សាពាណិជ្ជកម្មក្រៅប្រទេសតាមរយៈអ៊ីម៉ែល contact@crccef-ra.org ឬទូរស័ព្ទលេខ +334267734616 ឬចូលទៅកាន់គេហទំព័រ www.cnccef.org។ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកមន្ត្រីសម្របសម្រួលតាមរយៈទូរស័ព្ទលេខ +៨៥៥ ៨៦ ៣៣៣ ៩៣៣ / +៨៥៥ ៧៧ ៣៦១ ៨៣៦ ឬអ៊ីម៉ែល sorn.pitou@moc.gov.kh/oun.veasna@moc.gov.kh ឬតាមរយៈប្រព័ន្ធទូរស័ព្ទសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ១២៦៦៕

**សូមអរគុណ!**

សម្រាប់ចុះឈ្មោះ

GO.gov.kh